**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ ...០០១ សរ

ភ្នំពេញ, ថ្ងៃទី...០៤.....ខែ...វិច្ឆិកា...ឆ្នាំ ២០០៥

# សារាចរណែនាំ
## ស្តីពី
## ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតំរូវឱ្យគ្រប់ក្រសួង-ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និង ខេត្ត-ក្រុង អនុវត្ត និងធានានូវការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានម៉ត់ចត់ គង់វង្ស និង ប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព នៃសេដ្ឋកិច្ច ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន ។ ផ្អែកតាមបទបញ្ជានេះ ក្រសួងមហាផ្ទៃ ធ្វើការណែនាំដល់គ្រប់ បណ្តាអង្គភាពក្រោមឱវាទ លើការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋដល់អង្គភាពនីមួយៗ ដែលកំពុងគ្រប់គ្រងថែរក្សា ប្រើប្រាស់ ។ ដូចនេះ ដើម្បីពង្រឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានម៉ឺងម៉ាត់ស្របតាម នីតិវិធីហិរញ្ញវត្ថុ ចៀសវាងការចាត់ចែង និង ប្រើប្រាស់ដោយរំលោភបំពានលើផ្លូវច្បាប់ ដែលបណ្តាលឱ្យខូចខាត ឬ បាត់បង់ទ្រព្យសម្បត្តិរបស់រដ្ឋជាយថាហេតុ ព្រមទាំងប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ ។

ដើម្បីធានាឱ្យការប្រព្រឹត្តទៅមានតម្លាភាព ក្រសួងមហាផ្ទៃបានដាក់ចេញនូវវិធានការណែនាំមួយចំនួនដល់គ្រប់បណ្តាអង្គភាព ទាំងផ្នែករដ្ឋបាលស៊ីវិល និងផ្នែកសន្តិសុខសាធារណៈទាំងអស់ ក្រោមឱវាទក្រសួងដូចតទៅ :

## I. __គោលការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ__ :

ទ្រព្យសម្បត្តិទាំងឡាយដែលបានកំណត់ជាទ្រព្យសម្បត្តិរដ្ឋ ដូចមានចែងក្នុងមាត្រា ៥៨ ជំពូក៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ហើយបាន និង កំពុងស្ថិតនៅក្នុងដែនកាន់កាប់របស់អាជ្ញាធរ និង សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលត្រូវបានអង្គភាព ស្ថាប័ននីមួយៗ កំពុងគ្រប់គ្រង ថែរក្សា ប្រើប្រាស់ ។ រាល់ទ្រព្យសម្បត្តិទាំងអស់នោះត្រូវបានច្បាប់ កំណត់ជាទ្រព្យសម្បត្តិរបស់រដ្ឋដោយច្បាប់ រួមមានទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។

### ១. __ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ__ :

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មាន ០២ ផ្នែកគឺ : ផ្នែកអចលនទ្រព្យ និង ចលនទ្រព្យ ។

### ក. __អចលនទ្រព្យ__ :

ទីតាំងដីសំណង់-អគារ ការិយាល័យ ស្ថិតនៅតាមបណ្តាអង្គភាពនីមួយៗ កំពុងប្រើប្រាស់ និង ថែរក្សាត្រូវបានកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋ ផ្ញើជូនក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយក្តីមិនទាន់បានកត់ត្រាក្តី ជាដីទំនេរមិនទាន់បានប្រើប្រាស់ក្តី ដី-អគារបានប្រគល់ឱ្យឯកជនជួលកាន់កាប់ធ្វើអាជីវកម្ម ២

ហើយក្តី ឬ ដីសំណង់អគារ ដែលមន្ត្រី ឬ ប្រជាពលរដ្ឋបានយកមកស្នាក់នៅបណ្តោះអាសន្នក្តី រាល់ទីតាំងដី-អគារទាំងនេះត្រូវកំណត់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ហើយរដ្ឋបានផ្តល់សិទ្ធិជូននីតិបុគ្គលសាធារណៈទាំងឡាយតំណាងឱ្យសាមីក្រសួង-ស្ថាប័ន-អាជ្ញាធរដែនដី អង្គភាពរបស់រដ្ឋនីមួយៗ សំរាប់ទទួលខុសត្រូវលើការធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុរបស់រដ្ឋ-ការធ្វើសារពើភ័ណ្ឌ-ការលុបចេញពីបញ្ជីសារពើភ័ណ្ឌ ព្រមទាំងការចុះហត្ថលេខាលើលិខិតបទដ្ឋានផ្សេងៗ ស្របតាមគោលការណ៍នៃច្បាប់ ។ ចំពោះនីតិបុគ្គលសាធារណៈអាចមានសិទ្ធិប្រតិបត្តិទៅបាន លុះត្រាតែមានការប្រគល់សិទ្ធិជាផ្លូវការពីរាជរដ្ឋាភិបាល ឬរដ្ឋមន្ត្រីដែលទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងក្រសួង ។

**ខ. ចលនទ្រព្យរបស់រដ្ឋ : រួមមាន ០៣ ប្រភេទ :**

-សំភារៈបរិក្ខា-ឧស្សាហកម្ម (ឧទាហរណ៍ម៉ាស៊ីនភ្លើង 100KVA ម៉ាស៊ីនផលិត ឬ កែច្នៃធុនធ្ងន់)

-រថយន្ត និង គ្រឿងចក្រ (ឧទាហរណ៍ រថយន្តដឹកជញ្ជូន រថយន្តស៊ីវិល រថយន្តអគ្គីភ័យ រថយន្តទេសចរណ៍ ម៉ូតូ អូប័រ កាណូត ត្រាក់ទ័រ ម៉ាស៊ីនភ្លើងធុនមធ្យម ។ល។)

-សំភារៈសង្ហារឹម (ឧទាហរណ៍ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូកូពី កាមរ៉ាថត ទូរទស្សន៍ តុ ទូ កៅអី វិទ្យុទាក់ទងគ្រប់ធុន ។ល។

រាល់សំភារៈខាងលើ ទោះបីបានមកពីក្រសួងផ្តល់ សប្បុរសជនផ្តល់ ជាជំនួយអង្គការជាតិ-អន្តរជាតិក្នុង ឬ ក្រៅប្រទេសផ្តល់ ត្រូវបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមការណែនាំរបស់ជំនាញ ដោយថែរក្សាប្រើប្រាស់ និងចាត់ចែង ទៅតាមប្រព័ន្ធច្បាប់របស់រដ្ឋ ដែលបានកំណត់ ។

**គ. ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ :**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋកំពុងស្ថិតនៅក្នុងដែនអាជ្ញាធរសមត្ថកិច្ច គ្រប់គ្រងទាំងនោះ រួមមានបឹងធម្មជាតិ ប្រាំងទន្លេ ស្ទឹង ព្រែក ដីកោះ ផ្លូវលំ ផ្លូវជាតិ ផ្លូវដែក ឆ្នេរ សមុទ្រ ព្រៃឈើ ភ្នំ សួនច្បារ ឧទ្យានសាធារណៈ ដីចំណីផ្លូវ ដីទំនេរ កំពង់ផែ ព្រលានយន្តហោះ ធនធានរ៉ែធម្មជាតិ ។ល។ ទ្រព្យទាំងនេះត្រូវបានកំណត់ដោយ ច្បាប់ ។

## II. វិធានការសំរាប់អនុវត្ត :

ចាប់ពីថ្ងៃនេះតទៅ ត្រូវផ្អាករាល់ការលក់ ផ្ទេរ ដោះដូរ ជួល ឬ ផ្តល់ឱ្យជាសម្បទាននូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង នីតិបុគ្គល សាធារណៈទាំងឡាយលើកលែងតែមានច្បាប់ អនុក្រឹត្យ និង លិខិតបទដ្ឋានសំរាប់អនុវត្តត្រឹមត្រូវ ។

-ច្បាប់ស្តីពីសម្បទាន (សំរាប់ឱ្យវិស័យឯកជន ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ) និង លិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ ។

-អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

-អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ✓

-អនុក្រឹត្យស្តីពីនីតិវិធីនៃការលក់ ការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈស្របតាមមាត្រា ១៥ និង ១៧ នៃច្បាប់ភូមិបាល ។

រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ (ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ) មាន :

**ក. ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ :**

-ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចត្រូវបានលក់ ផ្ទេរ ជួល ឬ ផ្តល់ឱ្យជាសម្បទានផ្សេងៗបានឡើយ លុះត្រាតែទ្រព្យសម្បត្តិសាធារណៈទាំងនោះ ត្រូវបានកំណត់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈស្របតាមបទបញ្ញត្តិច្បាប់ ។ ពុំអាចមានបុគ្គលណាមួយមានសិទ្ធិកាន់កាប់ ប្រើប្រាស់ លក់ ដូរ ជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបានជាដាច់ខាត ។

**ខ. ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ :**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់កំពុងស្ថិតនៅក្នុងការប្រើប្រាស់ ថែរក្សា របស់អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលស៊ីវិលមាន : (ឧទាហរណ៍ ដី អគារ សំណង់ សាលាខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ និង សំណង់រដ្ឋបាលមួយចំនួនទៀត ។ល។

ផ្នែកសន្តិសុខសាធារណៈមាន : ដី អគារ សំណង់ ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង អធិការដ្ឋាន នគរបាលខណ្ឌ-ស្រុក ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ និងទីតាំង-អគារ ដែលកំពុងឈរជើងបំពេញការងារ ដោយឡែកមួយចំនួនទៀត ។ល។ ទ្រព្យទាំងនេះត្រូវបានកំណត់ជាទ្រព្យសម្បត្តិរដ្ឋដោយច្បាប់ ។

**គ. ទិដ្ឋភាពការម៉ឺងម៉ាត់ :**

លក្ខខណ្ឌទាំងឡាយនិង នីតិវិធីនៃការលក់ ដោះដូរ ផ្ទេរ ជួល និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈដែលកំណត់ដោយអនុក្រឹត្យ ។ គ្មានការលក់ ដោះដូរ ផ្ទេរ ជួល ទ្រព្យសម្បត្តិរបស់រដ្ឋមួយណាអាចប្រព្រឹត្តិទៅបាន ដោយមិនបំពេញតាមនីតិវិធី ផ្អែកតាមអនុក្រឹត្យបានឡើយ ។ ហើយគ្មានការចាប់ ឬ កាត់យកដីរបស់អង្គភាពរដ្ឋ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមទំនើងចិត្តណាមួយអាចកើតមានឡើងជាដាច់ខាត ។

## III. ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈស្របតាមបទបញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុ :

ចំពោះឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានអនុញ្ញាតដោយមាត្រា ៨១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ គឺត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ប្រកបដោយតម្លាភាព និង ម៉ឺងម៉ាត់បំផុតតាមការកំណត់នៃបទបញ្ញត្តិច្បាប់ និង លិខិតបទដ្ឋានជាធរមាន រួមមានជាអាទិ៍ អនុក្រឹត្យលេខ ៣៨អនក្រ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៩៩៥ និង អនុក្រឹត្យលេខ ៤៩ អនក្រ បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ និង បទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ ព្រមទាំង សារាចរស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលេខ ០០១ សរ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៩ របស់ក្រសួងមហាផ្ទៃ ។ល

**IV. ការគ្រប់គ្រងសម្បទាន :**

ក្នុងរយៈពេលរង់ចាំ **ច្បាប់ស្តីពីសម្បទាន** ចាប់ពីពេលនេះតទៅ ការផ្តល់សម្បទាននានា ត្រូវអនុវត្តនីតិវិធី នៃការដេញថ្លៃជាសាធារណៈ ប្រកបដោយតម្លាភាព លើមូលដ្ឋាននៃសៀវភៅបន្ទុកត្រឹមត្រូវ និង ច្បាស់លាស់ ។

**V. ការប្រគល់សិទ្ធិ :**

រាល់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ស្ថិតនៅក្នុងដែនអាជ្ញាធរ និង សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដែលបាននឹងកំពុងគ្រប់គ្រង ប្រើប្រាស់ និង ថែរក្សា រដ្ឋប្រគល់សិទ្ធិឱ្យតែគ្រប់គ្រងថែរក្សា និង ប្រើប្រាស់ទៅលើវិស័យនានារបស់ រដ្ឋដែលបំរើឱ្យផលប្រយោជន៍សាធារណៈ និង សង្គមតែប៉ុណ្ណោះ ។ ហើយត្រូវហាមឃាត់ដាច់ខាតនូវ ការលក់ ដូរ ផ្ទេរ ជួល ទ្រព្យសម្បត្តិរដ្ឋ ខុសគោលការណ៍នៃច្បាប់ ក្នុងករណីមានការលក់ ដូរ ផ្ទេរ ជួល សម្បទាននូវទ្រព្យសម្បត្តិរដ្ឋណាមួយដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែអនុវត្តតាមនីតិវិធី ដែលមានចែង នៅក្នុងអនុក្រិត្យ ។

**VI. អវសានបញ្ញត្តិ :**

ក្រោយពីបានទទួលនូវសារាចរណែនាំនេះ រាល់អាជ្ញាធរដែនដី គ្រប់បណ្តាថ្នាក់ និងកងកម្លាំងនគរបាលជាតិទាំងអស់ក្រោមឱវាទក្រសួងមហាផ្ទៃ ត្រូវយកចិត្តទុកដាក់ ធ្វើការណែនាំជំរុញ ការផ្សព្វផ្សាយអោយបានយល់ដឹងពីគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានពង្រឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់គ្រប់បណ្តាមូល ដ្ឋានថ្នាក់ក្រោមសំរាប់អនុវត្តឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងព្រះហស្តលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

***ចម្លងជូន :***

- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជ្រាប)
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាលស៊ីវិល
- អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត-ក្រុង ( ដើម្បីអនុវត្ត)
- គ្រប់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ